គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា
Committee for Free and Fair Elections in Cambodia
ខុមហ្វ្រែល COMFREL

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

# សេចក្តីជូនដំណឹង

**គណៈកម្មាធិការ ខុមហ្វ្រែល** មានកិត្តិយសសូមជម្រាបជូនដំណឹងដល់លោកលោកស្រី នាងកញ្ញា តំណាងសារព័ត៌មាន វិទ្យុ ទូរទស្សន៍ជាតិ អន្តរជាតិ ព្រមទាំងអង្គការជាតិ និងអន្តរជាតិទាំងអស់ មេត្តាជ្រាបថា គណៈកម្មាធិការខុមហ្វ្រែល នឹងរៀបចំសិក្ខាសាលាសម្លេងម្ចាស់ឆ្នោតស្តីពី "**ការកំណត់តម្រូវការជាអាទិភាពនៅឃុំ សង្កាត់ដាច់ស្រយាល**" ចំនួន០៤ នៅតាមទីកន្លែងដោយឡែកៗពីគ្នា។

សិក្ខាសាលានេះមានគោលបំណង បង្កើនការយល់ដឹងដល់ម្ចាស់ឆ្នោតអំពី សិទ្ធិ តួនាទី និងកាតព្វកិច្ចរបស់ម្ចាស់ឆ្នោត ក្នុងការអភិវឌ្ឍន៍នៅមូលដ្ឋាន និងបង្កើនឱកាសឱ្យម្ចាស់ឆ្នោត ចូលរួមក្នុងការពិភាក្សា ដើម្បីកំណត់តម្រូវការអាទិភាពក្នុងឃុំ សង្កាត់របស់ខ្លួន ហើយតម្រូវការជាអាទិភាពទាំងនេះ នឹងត្រូវបានចងក្រងជារបាយការណ៍ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន និងជម្រុញការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំសង្កាត់ និងការដាក់បញ្ចូលតម្រូវការក្នុងកម្មវិធីនយោបាយរបស់គណបក្សក្នុងឃុំ។

ខុមហ្វ្រែល នឹងអញ្ជើញវាគ្មិនជាក្រុមប្រឹក្សាឃុំ សង្កាត់ តំណាងគណបក្សនយោបាយក្នុងឃុំសង្កាត់ និងតំណាងអង្គការសង្គមស៊ីវិល ឬប្រធានសហគមន៍ដើម្បីចាប់អារម្មណ៍ទៅលើតម្រូវការជាអាទិភាពក្នុងឃុំសង្កាត់ដែលបានលើកឡើងដោយផ្ទាល់ពីប្រជាពលរដ្ឋនៅក្នុងឃុំសម្រាប់ផ្តល់ជូនគណបក្សនយោបាយ និងមន្ត្រីជាប់ឆ្នោតបំពេញ។

សេចក្តីជូនដំណឹងនេះ ចាត់ទុកជាការអញ្ជើញដល់លោក លោកស្រី នាងកញ្ញា តំណាងសារព័ត៌មាន វិទ្យុ ទូរទស្សន៍ជាតិ អន្តរជាតិ ព្រមទាំងអង្គការជាតិ និងអន្តរជាតិទាំងអស់ចូលរួមយកព័ត៌មានតាមការគួរ។

## ទីកន្លែង និងកាលបរិច្ឆេទសិក្ខាសាលាសម្លេងម្ចាស់ឆ្នោត

| ល.រ | ថ្ងៃខែឆ្នាំរៀបចំ | ឃុំ/សង្កាត់ | ក្រុង/ស្រុក/ខណ្ឌ | រាជធានី/ខេត្ត | ឈ្មោះទំនាក់ទំនង | ទូរសព្ទ |
|---|---|---|---|---|---|---|
| ១ | ១២/០៩/២០១១ | បាតាង | លំផាត់ | រតនៈគីរី | **លោក ជួន ភនដារ៉ា** | **០១២ ៥៨៧ ០១២** |
| ២ | ១៥/០៩/២០១១ | សាមគ្គី | អូរជុំ | | | |
| ៣ | ១៨/០៩/២០១១ | ស្រែខ្ទុម | កែវសីម៉ា | មណ្ឌលគីរី | **អ្នកស្រី កែវ ឌីរ៉េ** | **០១២ ៥០៧ ៦១៩** |
| ៤ | ១៩/០៩/២០១១ | ធ្មា | ជ័យសែន | ព្រះវិហារ | **អ្នកស្រី លន់ ស៊ីថាន់** | **០១២ ៨៩១ ៦២៧** |

*សូមរក្សាសិទ្ធិកែប្រែក្នុងករណីចាំបាច់ !*

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៦ ខែ កញ្ញា ឆ្នាំ ២០១១*

**ព័ត៌មានបន្ថែមសូមទំនាក់ទំនង ៖**

លោកស្រី ៖ **ហេង សុគន្ធា** (០១៧ ៥៨៣ ៨៦៩)

ទីស្នាក់ការកណ្តាល ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office : #138, Street. 122, TeukLaak I, TuolKork, Phnom Penh, CAMBODIA.
P.O. Box1145, Phone : (855) 23 884 150 Fax: (855) 23 885 745 E-mail : comfrel@online.com.kh Website: www.comfrel.org